# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់លើការកំណត់បញ្ជីថ្លៃលក់អគ្គិសនី តាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូតឱ្យសេវាករ សើ ទាងកុក ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់នូវនៅ នៅឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជំរាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ សើ ទាងកុក ឱ្យបានជ្រាបថា ដោយសារស្ថានភាពតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ និងដើម្បីកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករអគ្គិសនីមានអត្រាថ្លៃលក់ត្រឹមត្រូវ និងយុត្តិធម៌ អាជ្ញាធរអគ្គិសនីកម្ពុជាបានចាត់តាំងមន្ត្រីជំនាញចុះទៅកាន់ទីតាំងធ្វើសេវាកម្មអគ្គិសនីរបស់សេវាករ ដើម្បីពិនិត្យវាស់អត្រាប្រើប្រាស់ប្រេង បរិមាណថាមពលផលិត និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងការធ្វើសេវាកម្មអគ្គិសនីរបស់សេវាករ ដោយបានអញ្ជើញតំណាងសាលាឃុំ និងតំណាងអ្នកប្រើប្រាស់នៅក្នុងតំបន់របស់សេវាករ ដើម្បីចូលរួមជាអ្នកអង្កេតការណ៍ រួចយកមកធ្វើការសិក្សាថ្លៃដើមអគ្គិសនី និងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការធ្វើសេវាកម្មអគ្គិសនី ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ៩៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី។ តាមស្ថានភាពតម្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ដូចនេះ ដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់អគ្គិសនី និងស្ថានភាពហិរញ្ញវត្ថុរបស់សេវាករ និងដើម្បីឱ្យមានយុត្តិធម៌និងសមធម៌ រវាងអ្នកប្រើប្រាស់អគ្គិសនីនិង សេវាករផង អាជ្ញាធរអគ្គិសនីកម្ពុជា បានគណនាថ្លៃដើមអគ្គិសនី និងគ្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូត ដូចក្នុងតារាងខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **360** | **425** | **490** | **555** | |
| ថ្លៃដើមអគ្គិសនី (រៀល/គ.វ.ម៉) | 1,995 | 2,103 | 2,211 | 2,319 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **2,300** | **2,400** | **2,500** | **2,600** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **620** | **685** | **750** | **815** | |
| ថ្លៃដើមអគ្គិសនី (រៀល/គ.វ.ម៉) | 2,428 | 2,536 | 2,644 | 2,752 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **2,700** | **2,800** | **2,900** | **3,000** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **880** | **945** | **1,010** | **1,075** | |
| ថ្លៃដើមអគ្គិសនី (រៀល/គ.វ.ម៉) | 2,860 | 2,968 | 3,076 | 3,184 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,100** | **3,200** | **3,300** | **3,400** | |

| | | | | | |
|---|---|---|---|---|---|
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,140** | **1,205** | **1,270** | **1,335** | |
| ថ្លៃដើមអគ្គិសនី (រៀល/គ.វ.ម៉) | 3,293 | 3,401 | 3,509 | 3,617 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,500** | **3,600** | **3,700** | **3,800** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,400** | **1,465** | **1,530** | **1,595** | |
| ថ្លៃដើមអគ្គិសនី (រៀល/គ.វ.ម៉) | 3,725 | 3,833 | 3,941 | 4,050 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,900** | **4,000** | **4,100** | **4,200** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,660** | **1,725** | **1,790** | **1,855** | |
| ថ្លៃដើមអគ្គិសនី (រៀល/គ.វ.ម៉) | 4,158 | 4,266 | 4,374 | 4,482 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **4,300** | **4,400** | **4,500** | **4,600** | |

តាមតារាងខាងលើ នៅពេលថ្លៃប្រេងម៉ាស៊ូតឡើងថ្លៃ ឬចុះថ្លៃតាមចំនួនកំណត់ក្នុងតារាងខាងលើ ពេលនោះ អត្រាថ្លៃលក់អគ្គិសនីរបស់សេវាករអាចឡើង ឬចុះតាមចំនួនកំណត់ក្នុងតារាងខាងលើ។

ដើម្បីឱ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឱ្យក្រសួង–ស្ថាប័ន របស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសាធារណជនទាំងអស់មេត្តាពិនិត្យ និងផ្តល់មតិលើឯកសារគណនា វិភាគ វាយតម្លៃកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករ ជាតារាងថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូត ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០**។ ក្រោយថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ ឯកសារគណនា វិភាគវាយតម្លៃបញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តលើតារាងបញ្ជីថ្លៃលក់នេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឱ្យ **ការផ្តល់យោបល់មកឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងអាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៩៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ហើយសូមឱ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឱ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកធ្វើសេវាកម្មអគ្គិសនីផង**។

ឯកសារស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់សេវាករ ឯកសារគណនា វិភាគ វាយតម្លៃថ្លៃដើមអគ្គិសនី តារាងបញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូតលម្អិត ព្រមទាំងល័ក្ខខ័ណ្ឌសម្រាប់អនុវត្តយន្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូត ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ៩៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានតម្កល់ទុកនៅ.................................................................................. សម្រាប់សាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ មេត្តាជ្រាបជាពត៌មាន។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**